DECENT WORK
A better world starts here.

International Labour Organization

Media Advisory

# សិក្ខាសាលាស្តីពី ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និង ការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាននៅប្រទេសកម្ពុជា

សំរាប់ចេញផ្សាយបន្ទាន់: ថ្ងៃអង្គារ ទី4 ខែមិថុនា ឆ្នាំ២០១៣

**ខេត្តសៀមរាប (ពត៌មាន អង្គការILO)** – សិក្ខាសាលាដែលបានរៀបចំឡើងនៅខេត្តសៀមរាប កាលពីថ្ងៃទី៣០-៣១ខែឧសភា ឆ្នាំ២០១៣ ផ្តោតជាសំខាន់ទៅលើការចែករំលែកបទពិសោធន៍ និងគំនិតច្នៃប្រឌិតនានាក្នុងការអនុវត្តន៍ យុទ្ធសាស្ត្រជាតិគាំពារសង្គមនៅកម្ពុជា និងការរៀបចំបង្កើតសេវាគាំពារសង្គមជាមូលដ្ឋានថ្នាក់ជាតិនៅក្នុងអាស៊ាន។

សិក្ខាសាលាបច្ចេកទេសស្តីពី "ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន (SPF)" រៀបចំរួមគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការ ILO។

នៅក្នុងសន្ទរកថាបើកសិក្ខាសាលាដោយឯកឧត្តមបណ្ឌិត យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានមានប្រសាសន៍ថា "ភស្តុតាងថ្មីៗពីការសម្របសម្រួល និងការធ្វើសមាហរណកម្មគោលនយោបាយសង្គម រួមជាមួយនឹងការគ្រប់គ្រងករណីមួយចំនួន នឹងធ្វើឲ្យកាន់តែមានប្រសិទ្ធភាព និង ប្រសិទ្ធផលក្នុងការពង្រីក ការគ្របដណ្តប់សេវាគាំពារសង្គម និងការសម្របសម្រួលឈានទៅដល់ការកាត់បន្ថយភាពក្រីក្រ"។

បទពិសោធន៍ល្អៗពីប្រទេសជាង២៥ អំពីការអនុវត្តន៍ការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន ត្រូវបានលើកយកមកបង្ហាញ និងពិនិត្យនៅក្នុងសិក្ខាសាលាខាងលើ។ លើសពីនេះទៅទៀត កិច្ចពិភាក្សាបានផ្តោតលើសកម្មភាពដែលមានប្រសិទ្ធភាពក្នុងការរៀបចំបង្កើតយន្តការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន ដែលផ្អែកលើការសម្របសម្រួលថ្នាក់ជាតិ រួមជាមួយការអនុវត្តកម្មវិធីតាមរយះសេវាច្រកចេញចូលច្រកតែមួយ អនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ រឺបណ្តាញសង្គមស៊ីវិល។ សិក្ខាកាម បានឯកភាពនិងទទួលស្គាល់ថា ត្រូវតែមានប្រព័ន្ធព័ត៌មានដែលមានលក្ខណះសុខដុមនីយកម្ម និងការទទួលយោបល់ត្រលប់ដែលមានប្រសិទ្ធភាព រួមជាមួយវិធីសាស្ត្រនានាដែលអាចផ្តល់ពត៌មានទៅដល់អ្នកទទួលផល។ មានឯកសារយោងជាក់លាក់មួយចំនួនបានបង្ហាញការពិតថា អ្នកទទួលផលត្រូវតែបានចុះឈ្មោះ និងត្រូវបានផ្តល់អំណាចតាមរយះកញ្ចប់រួមមួយ ពីការផ្ទេរសេវាសង្គម ដើម្បីលើកកំពស់សក្តានុពលនៃវដ្តជីវិតរបស់មនុស្សម្នាក់ៗ។

កត្តាជារួមនៃអភិក្រមទាំងនេះ (គឺគោលគំនិតនៃសេវាចេញចូលច្រកតែមួយ) រួមចំណែកធ្វើឲ្យគោលការណ៍ណែនាំដែលមានចែងនៅក្នុងអនុសាសន៍របស់អង្គការILO ឆ្នាំ២០១២ លេខ២០២ ស្តីពីសេវាគាំពារសង្គមជាមូលដ្ឋាន ក្លាយជាការពិត។ ការផ្លាស់ប្តូរបទពិសោធន៍ពីប្រទេសប៉ែកខាងត្បូង នៅក្នុងព្រឹត្តិការណ៍នេះ បានផ្តល់ជាធាតុចូលយ៉ាងសំខាន់ ដល់គំរោងយន្តការផ្តល់សេវាសង្គមរបស់កម្ពុជា ដែលនឹងកំពុងចាប់ផ្តើមសាកល្បងនៅក្នុងស្រុកចំនួនពីរ នៃខេត្តសៀមរាប។

ឯកឧត្តម គឹម ឆៃហៀង អភិបាលរងខេត្តសៀមរាបបានមានប្រសាសន៍ថា ខេត្តយើងខ្ញុំបានត្រៀមខ្លួនរួចជាស្រេចក្នុងការសម្របសម្រួលអនុវត្តកម្មវិធីយន្តការផ្តល់សេវាសង្គម បង្កើនសមត្ថភាពអាជ្ញាធរថ្នាក់ក្រោមជាតិ និងត្រៀមខ្លួនចូលរួម និងគាំទ្រការពង្រីកការិយាល័យយន្តការសេវាគាំពារសង្គមនេះនាពេលអនាគត។

អង្គសិក្ខាសាលានេះបានផ្តល់វេទិកាសម្រាប់ប្រទេសជាច្រើនក្នុងការផ្សព្វផ្សាយ "គំរូល្អ និងគំនិតដ៏មានសារះប្រយោជន៍ ក្នុងការរៀបចំកិច្ចគាំពារសង្គមជាមូលដ្ឋានសំរាប់ប្រទេសនៅថ្ងៃអនាគត និងកិច្ចគាំពារសង្គមកំរិតខ្ពស់នៅថ្នាក់អាស៊ាន ក៏ដូចជាការរៀបចំគោលការណ៍អាស៊ានស្តីពីកិច្ចគាំពារសង្គម" នេះជាការពន្យល់របស់លោកស្រី Mega Irena ជំនួយការនាយក និងជាប្រធានផ្នែកសុខុមាលភាពសង្គមនៃលេខាធិការដ្ឋានអាស៊ាន។

លទ្ធផលនៃបទបង្ហាញ និងការពិភាក្សាក្នុងអង្គសិក្ខាសាលានេះ នឹងរួមចំណែកក្នុងការចងក្រងសៀវភៅណែនាំ ការអនុវត្តន៍ល្អ ផ្នែកកិច្ចគាំពារសង្គមជាមូលដ្ឋានរបស់អង្គការ ILO ស្តីពីការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋានដែលនឹងត្រូវបោះពុម្ពផ្សាយដោយអង្គការ ILO នៅដំណាច់ឆ្នាំនេះ។ សិក្ខាសាលានេះក៏បានផ្តល់ឪកាសសម្រាប់កិច្ចសហប្រតិបត្តិការនៃប្រទេសប៉ែកខាងត្បូងនាថ្ងៃអនាគតជាមួយប្រទេសផ្សេងៗដូចជា Labour Net (ឥណ្ឌា) ប្រេស៊ីល កូឡុំប៊ី ឆីលលី និងអាហ្សង់ទីន។ ដៃគូរអភិវឌ្ឍន៍ទាំងនេះបានបញ្ជាក់ពីបំណងក្នុងការផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់ការអនុវត្តន៍ផ្នែកកិច្ចគាំពារសង្គមជាមូលដ្ឋាន និងយន្តការច្រកចេញចូលតែមួយក្នុងតំបន់អាស៊ាន ហើយនិងផ្តល់ការណែនាំក្នុងការរៀបចំ និងអនុវត្តគោលការណ៍គាំពារសង្គមរបស់អាស៊ាន។

សិក្ខាសាលានេះចូលរួមដោយសិក្ខាកាម ១២០រូបមកពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន ឥណ្ឌា ម៉ុងហ្គោលី ប៉ាគីស្ថាន កោះវ៉ានូទូ និងកោះសូឡូម៉ង់ អាហ្វ្រិកខាងត្បូង ណាមីប៊ីយ៉ា ហ្សំបៀ អាហ្សង់ទីន ប្រេស៊ីល ឆីលលី និង កូឡុំប៊ី។ គណៈអធិបតីក្នុងសិក្ខាសាលានេះរួមមានលោក Maurizio Bussi  នាយកក្រុមការងារសមរម្យរបស់អង្គការ ILO តំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក ឯកឧត្តម Jean-François Cautain ឯកអគ្គរដ្ឋទូត សហាគមន៍អឺរ៉ុបប្រចាំប្រទេសកម្ពុជា ឯកឧត្តម Yuji Kumamaru ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា លោកស្រី Claire Van der Vaeren អ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅកម្ពុជា លោក Francisco Simplicio ប្រធានផ្នែកកិច្ចសហប្រតិបត្តិការ ពិសេសនៃប្រទេសប៉ែកខាងត្បូងរបស់អង្គការ UNDP ប្រចាំទីក្រុងញូយ៉ក និងលោកស្រី Christine Bockstal ប្រធានប្រតិបត្តិការប្រចាំប្រទេស និងសហប្រតិបត្តិការបច្ចេកទេសនៃនាយកដ្ឋានកិច្ចគាំពារសង្គមរបស់អង្គការILO ប្រចាំទីក្រុងហ្សឺណែវ។

ព័ត៌មាន លំអិតសូមមើលគេហទំព័រ (http://www.social-protection.org/gimi/gess/ShowProjectPage.do?pid=2207)

ទំនាក់ទំនង:
អ្នកស្រី Valérie Schmitt  អ្នកជំនាញផ្នែកសន្តិសុខសង្គម ក្រុមការងារសមរម្យប្រចាំទីក្រុងបាងកក

Tel: +66 22 88 1767   Email: schmittv@ilo.org

អ្នកស្រី ឱក ម៉ាលីកា  មន្ត្រីទទួលបន្ទុកកម្មវិធី អង្គការILO ប្រចាំទីក្រុងភ្នំពេញ
Tel. +855 16 872 703   Email: malika@ilo.org